ព្រះរាជក្រឹត្យ

នស/រកត/០៩០៥/៤០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការតែងតាំង និងសកម្មភាពរបស់សាលាជំនុំជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមតំរូវការចាំបាច់នៃការងារ
- យោងតាមស្ថានភាពចាំបាច់ នៃការកែទម្រង់ប្រព័ន្ធច្បាប់ និង យុត្តិធម៌
- យោងតាមស្ថានភាពចាស់ជរា នៃចៅក្រម និង ព្រះរាជអាជ្ញា
- យោងតាមគោលការណ៍នៃសមត្ថកិច្ចជាប់ចំណង
- យោងតាមសំណើសុំបន្តការងាររបស់ចៅក្រម និង ព្រះរាជអាជ្ញាដែលមានអាយុចាប់ពី ៦០ ឆ្នាំ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ជូនចំពោះនាយករដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់អោយចូលនិវត្តន៍ចៅក្រម និង ព្រះរាជអាជ្ញា ដែលមានអាយុចាប់ពី ៦០ ឆ្នាំ ឡើងទៅ ។

មាត្រា ២ : ចៅក្រម ឬ ព្រះរាជអាជ្ញាមួយចំនួនអាចនៅបន្តការងារតាមការចាំបាច់ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ.០៥០៩.៤២៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០០៥

លេខ : ៣៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល